# Alameda County Behavioral Health Care Services

## ក្រដាសផ្តល់ពត៌មានអំពីថ្នាំពេទ្យ: **ថ្នាំបំបាត់ការព្រួយចិត្ត/Antidepressants**

[ ] fluoxetine (Prozac)
[ ] paroxetine (Paxil)
[ ] amitriptyline (Elavil)
[ ] clomipramine (Anafranil)
[ ] desipramine (Norpramin)
[ ] phenelzine (Nardil)
[ ] trazodone (Desyrel)
ថ្នាំផ្សេងទៀត: ______________________

[ ] sertraline (Zoloft)
[ ] protriptyline (Vivactil)
[ ] nortriptyline (Pamelor)
[ ] doxepin (Sinequan)
[ ] imipramine (Tofranil)
[ ] nefazodone (Serzone)
[ ] bupropion (Wellbutrin)

ថ្នាំបំបាត់ការព្រួយចិត្តគឺជាថ្នាំសំរាប់ព្យាបាលទុក្ខព្រួយ និងជួយធ្វើឲ្យអារម្មណ៍ទូទៅឲ្យបានល្អប្រសើរ អាចផ្តល់អារម្មណ៍បានសំរាន្តបាន ទទួលទានអាហារបាន និងធ្វើសកម្មភាពបាន។ បន្ថែមពីនេះ ថ្នាំនេះមានសារៈសំខាន់ណាស់ក្នុងការព្យាបាលរោគខ្វល់ចិត្ត។ តាមការប្រមាណទៅឃើញថាមានអ្នកជម្ងឺប្រាំបី ឬប្រាំបួននាក់ក្នុងចំណោមដប់នាក់ដែលមានទុក្ខព្រួយត្រូវបានព្យាបាលជាដោយសារថ្នាំបំបាត់ការព្រួយចិត្តដែលគេកំពុងប្រើសំរាប់សព្វថ្ងៃនេះ។

ពពួកថ្នាំបំបាត់ការព្រួយចិត្តទាំងអស់សុទ្ធតែមានប្រសិទ្ធិភាព ទោះបីជាថ្នាំខ្លះមានប្រសិទ្ធិភាពជាងថ្នាំខ្លះទៀតចំពោះអ្នកជម្ងឺខ្លះក៏ដោយ។ នេះគឺមកពី ថ្នាំមួយចំពូកវាមានប្រសិទ្ធិភាពពិសេសទៅលើមនុស្សម្នាក់ ហើយចំណែកមនុស្សម្នាក់ទៀត គាត់ទៅជាគាប់នឹងថ្នាំមួយជំពូកទៀត។ ថ្នាំបំបាត់ការព្រួយចិត្តនេះ ក៏ដូចជាថ្នាំឯទៀតដែរ តែងតែមានប្រតិកម្មខ្លះៗដូចជា:

| **មានជាទូទៅ** | **មិនសូវមាន** | **កម្រមាន** |
|---|---|---|
| ការទាល់លាមក | ព្រិលភ្នែក | ការវង្វេងវង្វាន់ |
| ការងុយងោក | ការប្រាស់ប្រាល/ការរំជើបរំជួល | ចង្វាក់បេះដូងរត់ខុសធម្មតា |
| ភាពវិលមុខ | ការឡើងទម្ងន់ | ប្រកាច់ |
| ស្ងួតមាត់ | ស្បែកឆាប់ចាញ់នឹងកំដៅថ្ងៃ | ការញ័រញាក់ |
| ការគង្វល់/ការរសាប់រសល់* | ការមិនសូវឃ្លានបាយ | សំដីញាប់ |
| ឈឺក្បាល | ការមិនសូវចូលចិត្តសេពកាម | ការកើនសកម្មភាព |
| រោគដេកមិនលក់* | ការចង្អោរ | |

ថ្នាំតែរោគព្រួយចិត្តធ្វើសកម្មភាពសន្សឹមៗ ដូច្នេះវាអាចត្រូវប្រើរយៈពេលជាច្រើនអាទិត្យទំរាំវាមានប្រសិទ្ធិភាពពេញលេញ។ សូមកុំអស់សង្ឃឹមឲ្យសោះ ព្រោះវាត្រូវតែប្រើពេលយូរបន្តិចហើយទំរាំនឹងខ្លួនរបស់អ្នកបានស្រួលឡើងវិញ។
សូមអ្នកចងចាំថា ថ្នាំទាំងនេះត្រូវតែទទួលទានឲ្យទៀងទាត់ទើបមានប្រសិទ្ធិភាពពេញលេញល្អ។

CAMBODIAN